# រឿងទី៥ ៖ ម៉ូសេ២

**ខគម្ពីរ៖**
**និក្ខមនំ៣:១០**

ឥឡូវនេះ យើងចាត់អ្នកឲ្យទៅជួបស្តេចផារ៉ោន។ ចូរទៅនាំជនជាតិអ៊ីស្រាអែល ជាប្រជារាស្ត្ររបស់យើងចេញពីស្រុកអេស៊ីប។

ម៉ូសេបានធំធាត់ឡើងនៅក្នុងវាំង ម៉ូសេបានក្លាយជាមនុស្សពេញវ័យ។
ម៉ូសេឈឺចាប់ជាខ្លាំងពេលឃើញជនជាតិអ៊ីស្រាអែលដែលកំពុងរស់ជាទាសករ រងការធ្វើទុក្ខទោស ពីជនជាតិអេស៊ីប។
មានថ្ងៃមួយ ម៉ូសេបានដើរឆ្លងកាត់កន្លែងជនជាតិអេស៊ីបធ្វើការ។
មានសាសន៍អេស៊ីបម្នាក់ បានវាយធ្វើបាបសាសន៍ហេព្រើរយ៉ាងសាហាវយង់ឃ្នង។
កាលម៉ូសេឃើញសាសន៍អេស៊ីបវាយធ្វើបាបសាសន៍ហេព្រើរដែលជាញាតិខ្លួនដូច្នេះ គាត់ខឹងសម្បារជាខ្លាំង។
គាត់ក៏បានសម្លាប់សាសន៍អេស៊ីបនោះនៅនឹងកន្លែងនោះតែម្តង។ ដំណឹងថាម៉ូសេបានសម្លាប់សាសន៍អេស៊ីបក៏លេចឮពេញក្នុងវាំង។
កាលស្តេចផារ៉ោនបានឮដំណឹងនោះភ្លាម ក៏រកម៉ូសេដើម្បីសម្លាប់។
ម៉ូសេបានរត់គេចពីពួកទាហានរបស់ស្តេចផារ៉ោនដែលមកតាមចាប់ខ្លួនគាត់ ទៅឯទីវាលរហោស្ថានម៉ាឌាន។
ម៉ូសេបានរស់នៅទីនោះធ្វើជាអ្នកគង្វាលចៀម។
ម៉ូសេបានភ្លេចអស់ពីឋានៈរបស់ខ្លួនដែលធ្លាប់ជាបុត្រានៃស្រុកអេស៊ីប ព្រមទាំងជនជាតិអ៊ីស្រាអែលទាំងអស់ដែល កំពុងជួបទុក្ខលំបាកក្នុងជីវិតជាទាសករនៅស្រុកអេស៊ីប។
មានថ្ងៃមួយ ម៉ូសេបានឡើងទៅឃ្វាលចៀមនៅលើភ្នំហូរែប។
នៅទីនោះ គាត់បានប្រទះឃើញហេតុការណ៍ដ៏ចម្លែកមួយ។
ពេលនោះ ស្រាប់តែព្រះសូរសៀងរបស់ព្រះជាម្ចាស់ក៏បន្លឺឡើង។
ម៉ូសេភ័យខ្លាចជាខ្លាំង ក៏យកដៃខ្ទប់មុខហើយឱនក្រាបចុះ។



«ម៉ូសេអើយ យើងបានទតឃើញពីការឈឺចាប់ដែលរាស្ត្រយើងកំពុងរងទុក្ខនៅក្នុងស្រុកអេស៊ីប យើងបានស្តាប់ឮ សម្រែកនៃការឈឺចាប់
និងទុក្ខវេទនារបស់ពួកគេ ពេលនេះ យើងនឹងឱ្យអ្នកចេញទៅជួបនិងស្តេចផារ៉ោន ហើយដឹកនាំរាស្ត្រយើងចេញពីស្រុកអេស៊ីប។
ពេលម៉ូសេស្តាប់ឮភ្លាម គាត់ភ័យខ្លាចជាខ្លាំង។
ភ្លាមនោះ ព្រះជាម្ចាស់ក៏មានបន្ទូលថាទ្រង់នឹងគង់នៅជាមួយម៉ូសេ។

ហើយទ្រង់ក៏ត្រៀមអើរ៉ុនជាបងប្រុសគាត់ដែលជាមនុស្សពូកែនិយាយឱ្យទៅជាមួយគាត់។

ហើយម៉ូសេ និងអើរ៉ុនក៏ធ្វើដំណើរចេញទៅស្តេចផារ៉ោននៅក្នុងស្រុកអេស៊ីប។

ម៉ូសេបាននិយាយទៅស្តេចផារ៉ោនថា៖ «សូមទ្រង់អនុញ្ញាតឱ្យប្រជារាស្ត្រអ៊ីស្រាអែលទាំងអស់ចេញទៅទីវាលរហោស្ថានដើម្បីថ្វាយយញ្ញបូជាដល់ព្រះជាម្ចាស់»។

ដោយផារ៉ោនស្តេចស្រុកអេស៊ីប មានចិត្តចង់ទុករាស្ត្រអ៊ីស្រាអែលធ្វើជាទាសកររហូត ទ្រង់មិនអនុញ្ញាត ឱ្យពួកគេចេញទៅទេ។

ហើយថែមទាំងធ្វើបាបឱ្យជនជាតិអ៊ីស្រាអែលធ្វើការកាន់តែធ្ងន់ជាងមុនទៀត។ ព្រះជាម្ចាស់ទ្រង់ក្រោធយ៉ាងខ្លាំង។

ដូច្នេះ ព្រះជាម្ចាស់ក៏ធ្វើឱ្យទឹកទន្លេទាំងអស់នៅស្រុកអេស៊ីបប្រែទៅជាឈាម។

ធ្វើឱ្យពួកសាសន៍អេស៊ីបគ្មានទឹកសម្រាប់បរិភោគ។ ប៉ុន្តែ ស្តេចផារ៉ោននៅតែមិនស្តាប់តាមដដែល។

ដូច្នេះ ព្រះជាម្ចាស់ក៏ធ្វើឱ្យស្រុកអេស៊ីបទទួលរងនូវគ្រោះកាចជាច្រើនទៀត មានដូចជា គ្រោះកាចកង្កែប ចៃ រុយ ជំងឺអាសន្នរោគ ជំងឺបូស ព្រិល កណ្តូប ភាពងងឹតអន្ធការ...។

យ៉ាងនេះក្តី ស្តេចផារ៉ោន នៅតែមិនព្រមឱ្យរាស្ត្រអ៊ីស្រាអែលចេញទៅដែរ។ ដូច្នេះ ទីបំផុត ព្រះជាម្ចាស់ក៏ធ្វើឱ្យមានគ្រោះកាចទីដប់កើតមានក្នុងស្រុកអេស៊ីប។

គ្រោះកាចទីដប់ បានធ្វើឱ្យកូនច្បងក្នុងស្រុកអេស៊ីបស្លាប់ទាំងអស់។

សូម្បីបុត្រាច្បងរបស់ស្តេចផារ៉ោនក៏ត្រូវស្លាប់ដែរ។

ស្តេចផារ៉ោនគ្មានជំរើសអ្វីក្រៅពី អនុញ្ញាតឱ្យរាស្ត្រអ៊ីស្រាអែលចាកចេញនោះទេ។

ទីបំផុត រាស្ត្រអ៊ីស្រាអែលទាំងអស់ បានចាកចេញពីស្រុកអេស៊ីបជាមួយម៉ូសេ។



**សកម្មភាពទី១** សូមឆ្លើយសំណួរខាងក្រោម។

a. តើអ្នកណាដែលចាត់ម៉ូសេទៅឯស្ដេចផារ៉ោន ដើម្បីរំដោះជនជាតិអ៊ីស្រាអែលពីស្រុកអេស៊ីប?

---

b. តើព្រះជាម្ចាស់បានសន្យាអ្វីជាមួយលោកម៉ូសេ ដើម្បីកុំឱ្យគាត់ភ័យខ្លាច?

---

c. តើព្រះជាម្ចាស់ដាក់គ្រោះកាចប៉ុន្មានយ៉ាងលើស្រុកអេស៊ីប?

---

d. តើស្ដេចផារ៉ោនសម្រេចចិត្តឱ្យជនជាតិអ៊ីស្រាអែលចេញទៅ ដោយសារគ្រោះកាចអ្វី?

---

- សូមអានខគម្ពីរ និងទន្ទេញខគម្ពីរ។ (និក្ខមនំ ៣:១០)

យើងចាត់អ្នកឲ្យទៅទៅរកស្ដេចផារ៉ោន ដើម្បីរំដោះជនជាតិអ៊ីស្រាអែលពីស្រុកអេស៊ីប
យើងចាត់អ្នកឲ្យទៅជួបស្ដេចផារ៉ោន។ ចូរទៅនាំជនជាតិអ៊ីស្រាអែល ជាប្រជារាស្ត្ររបស់យើងចេញពីស្រុកអេស៊ីប។

**សកម្មភាពទី២** សូមសរសេរគ្រោះកាចទាំង ១០ តាមលំដាប់លំដោយ។

គ្រោះកាចទី៨ កណ្តូប / គ្រោះកាចទី១ ទឹកក្លាយជាឈាម / គ្រោះកាចទី៣ មូស / គ្រោះកាចទី៦ ដំបៅពងបែក... 

| | | | |
|---|---|---|---|
| 1 | ទឹកក្លាយជាឈាម | 6 | ដំបៅបូស |
| 2 | | 7 | |
| 3 | មូស | 8 | កណ្តូប |
| 4 | | 9 | ភាពងងឹតអន្ធការ |
| 5 | | 10 | |